# សុន្ទរកថារបស់ លោក ហ្វូជីម៉ុតូ តូស៊ីគី
# លេខាទី២ ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការនូវ
# មជ្ឈមណ្ឌលសហគមន៍កសិកម្មខេត្តព្រះវិហារ
# ថ្ងៃទី ២៥ ខែតុលា ២០១៦

- សូមគោរព **ឯកឧត្តម លី សារារិទ្ធិ** អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ
- សូមគោរព **លោក ពឹង ទ្រីដា** ប្រធានមន្ទីរកសិកម្មខេត្តព្រះវិហារ
- សូមគោរព អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធនៅសហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ ក្នុងស្រុករវៀង ខេត្តព្រះវិហារ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម លី សារារិទ្ធិ** អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ ដើម្បីប្រារព្ធពិធីសម្ពោធមជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន៣។

កសិកម្ម គឺជាវិស័យដ៏មានសារៈសំខាន់នៃបណ្តាវិស័យដទៃទៀតនៅក្នុងប្រទេសកម្ពុជា ដែលបានរួមចំណែកដល់ចំណូលប្រជាជនប្រមាណជា ៣០% ដោយសារតែជាងពាក់កណ្តាលនៃដង់ស៊ីតេប្រជាជនជាកសិករ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃវិស័យកសិកម្មសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅប្រទេសកម្ពុជា រដ្ឋាភិបាលជប៉ុន បាននឹងកំពុងជួយគាំទ្រនូវកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈយន្តការច្រើនដែលក្នុងនោះរួមមាន៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់ជំនួយផ្នែកបច្ចេកទេសជាដើម។

ជំនួយឧបត្ថម្ភឥតសំណងរបស់ជប៉ុនទាំងអស់នេះ គឺអនុលោមតាមគោលនយោបាលរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្នុងនោះរួមមាន គោលនយោបាលអភិវឌ្ឍផ្នែកឧស្សាហកម្ម ក្នុងការលើកស្ទួយការនាំចេញអង្ករ ពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការបូកបន្ថែមនូវតម្លៃផលិតផលកសិកម្ម តាមរយៈការលើកស្ទួយផលិតកម្មស្បៀងអាហារ និងការគ្រប់គ្រងអោយបានត្រឹមត្រូវក្រោយពេលប្រមូលកសិផលជាដើម។

ក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហគមន៍កសិកម្មចំនួន៦០០ ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជា ហើយកសិករទាំងអស់ កំពុងតែព្យាយាមក្នុងការកែលម្អជីវភាពរស់នៅ តាមរយៈមុខរបរអាជីវកម្មរបស់ខ្លួន។ យ៉ាងណាមិញ ខ្ញុំទទួលស្គាល់ថា កសិករនៅតែជួបផលលំបាកជាច្រើនផងដែរ។ ខ្ញុំទទួលបានដំណឹងថា កសិករនៅក្នុងខេត្តព្រះវិហារនេះ មានផលលំបាកក្នុងការលក់អង្ករ និងសណ្តែកសៀងក្នុងតម្លៃមួយសមរម្យ ដោយសារតែកង្វះខាតមិនត្រឹមតែម៉ាស៊ីនកសិកម្មប៉ុណ្ណោះទេ ថែមទាំងកង្វះខាតនូវឃ្លាំងស្តុកកសិផល និងឧបករណ៍ផលិតកម្មមួយចំនួនផងដែរ។

ឥឡូវនេះ ខ្ញុំមានសេចក្តីរីករាយដែលបានឃើញមជ្ឈមណ្ឌលសហគមន៍កសិកម្មថ្មីនេះ ត្រូវការសាងសង់ឡើងក្រោយជំនួយឧបត្ថម្ភឥតសំណងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ មជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន៣ និងម៉ាស៊ីនកសិកម្មមួយចំនួនរួមមាន៖ គោយន្តកន្ត្រៃចំនួន ០៣គ្រឿង ម៉ាស៊ីនបោកស្រូវចំនួន ០២គ្រឿង ម៉ាស៊ីនបោកសណ្តែកសៀងចំនួន ០១គ្រឿង និងឡសម្ងួតស្រូវចំនួន ០១កន្លែង ក៏ត្រូវបានសាងសង់ និងផ្តល់ជូនដល់សហគមន៍កសិកម្មចំនួន៣

ដែលក្នុងនោះរួមមាន៖ សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ ស្ថិតនៅក្នុងស្រុករវៀង សហគមន៍កសិកម្មអូរខ្លែងពណ៌ ស្ថិតនៅក្នុងក្រុងព្រះវិហារ និងសហគមន៍កសិកម្មក្របៅព្រហ្មទេព ស្ថិតនៅក្នុងស្រុកគូលែន។

នៅក្នុងសន្ទរកថានេះ ខ្ញុំសូមលើកឡើងនូវបីចំនុចសំខាន់ៗ។ ចំនុចទី១ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ការនាំចេញអង្ករបស់កម្ពុជា មានការកើនឡើងដែលត្រូវបានចាត់ទុកថាជាអង្ករដែលមានគុណភាពខ្ពស់លើពិភពលោក។ ខ្ញុំជឿជាក់ថា ការផ្តល់ជំនួយឧបត្ថម្ភនៅថ្ងៃនេះ នឹងជួយបង្កើនការផលិតអង្ករដែលមានគុណភាពខ្ពស់បន្ថែមទៀត។

ចំនុចទីពីរ ខ្ញុំសង្ឃឹមថា កសិករកាន់តែច្រើន នឹងអាចបង្កើនប្រាក់ចំណូល និងគុណភាពនៃជីវិតរបស់ពួកគេកាន់តែល្អប្រសើរជាងមុន ជាមួយនឹងការកែលម្អមុខងារនៃមជ្ឈមណ្ឌលសហគមន៍កសិកម្មទាំងបី។ គម្រោងនេះ ត្រូវបានរំពឹងថា អតិថិជនកាន់តែច្រើន នឹងអាចទទួលបាននូវអង្ករកម្ពុជាដែលមានគុណភាពល្អ។

ចំនុចទីបី ខ្ញុំសូមស្នើដល់កសិករទាំងអស់ជួយថែទាំមជ្ឈមណ្ឌលសហគមន៍កសិកម្ម និងម៉ាស៊ីនកសិកម្មទាំងអស់នេះអោយនៅគង់វង្សល្អ ដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាទីបញ្ចប់នេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ ដែលបានរួមចំណែកក្នុងការអនុវត្តនូវគម្រោងនេះអោយបានបញ្ចប់ទៅដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**